Khmer Story Lovers

# [illegible]

ទីចាត់ការនៃក្រុមអ្នកនិពន្ធមាតុភូមិផ្ទះលេខ ២៥ ផ្លូវលេខ ២៨៩ ដីឡូត៍លេខ ២៩៨ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



ស៊ុយពានម្ចាស់ដេញតាមទាន់ក្បាលពោះបាងសានឆិងលីសៃ បងរំដោះខ្លួនចេញពីមារណពល្បើ យ៉ាងណាក៏ធ្វើទៅមិនកើត ព្រោះមារណពដើរតាមក្រោយជាប់ស្អិត.. ថែមទាំងពោលសរសើរពីក្រោយខ្នងទៀតថា:

លោកបងទាំងពីរពូកែមែនហ្ន៎ ! តែលឿនម្ល៉េះ ដូចអត់ខំប្រឹងសោះ ! ខ្ញុំឯណេះវិញប្រឹងតែតាមសឹងដាច់ខ្យល់ហើយ !

និយាយពីកម្លាំងជាតុ ឃើញថាខុសគ្នាឆ្ងាយណាស់ គឺបាងសានឆិងលីសៃសំកាល់ខ្លួនដោយមិនបាច់ប្រឹងប្រែង, ចំណែកស៊ុយពានបោះជំហានវែងៗ បង់ពោយចំកោងខ្លួនដូចគេគេប្រណាំង តែសម្ដែងខាងនៅមូលដ្ឋានដែល បញ្ជាក់ឲ្យឃើញថា ខាងផ្នែកហាត់សោះទេ ។ បើចេះសំកាល់ខ្លួនដូចគេដែរ ជួនទាំងពីរពិតជារឹតតែស្ញប់សរសើរខ្លាយទៀតមិនខាន ។

ស៊ុយពានឃើញជនទាំងពីរស្រួតរូតគម្រង់ក្លួមនៅខាងលោង ដាដំៈ សម្ងាត់របស់ក្រុមបក្សក្នែកកក្ដាញ់ក្រញាំង រំឭកគេថា :

-លោកបងទាំងពីរ, ជិតដល់កន្លែងគ្រោះថ្នាក់ហើយ, គោងរកផ្លូវដើរពាំង ដើម្បីមិនឲ្យស្ដាប់អសារបង់ ។

បាងសានឆិងលីសៃឈប់ងាក់មុខគ្នា ហើយបកក្រោយសួរ :

អ្នកប្រែសម្រួល : អ.គឹមសាន

តម្លៃ ៣៖០០

ផ្សាយចេញពីក្រុមអ្នកនិពន្ធ

« មាតុភូមិ »

ភ្នំពេញ

លេខ ២៤

- ម៉េចឯងដឹងថាជិតដល់កន្លែងគ្រោះថ្នាក់ ?

- ព្រោះនៅខាងមុខជាភូមិនេសាទមួយតូចដែលមានអ្នកគុននិយមជាច្រើនលាក់ខ្លួនមិនឲ្យគេស្គាល់ ហេតុនេះខ្ញុំយល់ថាកាលណាគេឃើញយើងចាំងថៃ គេនឹងសម្លាប់ចោលឥតសាវតារការណ៍ !

លីសៃប្រែទឹកមុខ សួរបញ្ជាក់ :

- ម៉េចឯងដឹងអីចឹង ?

ស៊ីផានប៉ណា លៀងការនាយពួនក្នុងឃ្លុបទូកស្តាប់ក្រុមប្លន់ដែកដៃគ្នា ហេតុគេនាំគ្នាពួនសម្ងំក្នុងភូមិនេសាទ ស្ងាត់អស់ជូនបងធម៌ចាំងពីស្តាប់ហូរហៃ ។ លីសៃបញ្ជាក់ :

គេពួនក្នុងភូមិនេសាទដែលប្អូននិយាយនោះ មកពីគេខ្លាចសេនាបញ្ជាមណ្ឌលរកឃើញណា ! គ្មានទាក់ទងអីជាមួយយើងទេ, ម៉េចឯងខ្លាចគេសម្លាប់យើងវិញ?

ស៊ីផានកាដៃញាប់ស្អេក :

- ទេ ! ទេ ! កុំចៅ ! ពួកចោរគាបសាហាវណាស់ គេសម្លាប់មនុស្សដូចសម្លាប់សត្វស្រមោចអីចឹង ! គ្រាន់តែចង់ក្លាការសម្ងាត់មិនឲ្យលេចឮដល់អ្នកក្រៅ សូម្បីគ្នាឯងក៏គេសម្លាប់ឥតប្រណីដែរ ។ បងម៉េលណាមង្គលប្រឡាក់រាំងខ្ញុំជាណាមសេនាពីរនាក់ដែលពួកគេសម្លាប់ ផ្តាល់ថ្ងៃនោះណា !

អើ, លីឯងខ្លាចណាស់មិនបាច់ទៅតាមបងទៀតទេ ។

មាណពពោលឡើង :

- សូមលោកបងចាំងពីកុំទៅល្អជាង ។ មិន... មិនមែនស្រួលទេ ។

ហង់សានន័ងលីសៃនាំគ្នាលកទៅមុខទៀត លែងរវល់នឹកនាដល់ក្មេងល្ងីល្ងើដែលមានតែកម្លាំងកាយឥតប្រយោជន៍, យុទ្ធសិល្បៈអន់ខ្សោយចិត្តកំសាកញី ។

ស៊ីផានឲ្យគេរត់ទៅមុខ ឬនបន្តិចក៏រត់តាមក្រោយទៀត ។ ហង់សានសួរ :

- ម៉េងឯងខ្លាចក្រុមប្លន់ដែកសម្លាប់ចោល ម៉េចរត់តាមយើងទៀតហើយ ?

មាណពឆ្លើយយ៉ាំងម៉ាំ :

- ក្រែងពួកយើងសច្ចាស្បថស្បែថារួមសុខទុក្ខជាមួយគ្នាឬ? បងចាំងពីរចង់ទៅណា ខ្ញុំក៏ទៅរួមស្លាប់ក្នុងថ្ងៃជាមួយគ្នាដែរ, ខ្ញុំជាកូនប្រុសនិយាយម៉ាត់ណា ម៉ាត់ហ្នឹងហើយណា !

លីសែបំភ័យថា :

នៃប្អូនប្រុស, ពួកប្លុកដែក លើកប្លុកច្រូងប្រានបាក់ចំរុះលើកឯង ដូចគេបាក់ផ្កែកព្រៃអ៊ីចឹងណា, ឯងខ្លាចទេ ?

ស៊ីផានទឹកលល់កាល « បន្ទូ » សម្រាប់សមាជិកក្រុមប្លុកដែកពីនាក់ក្នុងទូក ដោយឥតវិនិច្ឆ័យ នាយត្រីក្បាលខ្លាក ៗ ឡើងសម្បុរតឹត្ដក់ ហាក់ដូចពុសវែ្រមកខ្មោចឆ្កៅនៃជនរងគ្រោះល្វើយ ៗ នឹងក្រពៀក , នាយតឹកថា :

- ភូមិនេសាទនោះ ទុកបើចក់មានមនុស្សពោរពេញយខាក់ដែរ តែរបងយមិចាំងពីរមានយុទ្ធសិល្ប៍ៈ ខ្លាំងខ្លួសយ៉ាងណាក៏មិនរាយណ្ហះដែរហើយទៅ ។

លីសែឃើញមាណពគិតបញ្ហា ផ្ដាស់ប្ដូរទឹកមុខ កំពោលចំអក :

- បងចាំងពីរសុខចិត្តទៅស្លាប់ហើយ ប្អូនឯងមិនបាច់ជរទេ, ត្រូវត្រឡប់ទៅផ្ទះវិញចុះ ។ បើបងមិនស្លាប់ យើងរកជួបគ្នាម្ដងទៀតនៅថ្ងៃក្រោយ ។

មាណពត្រីក្បាលមួយៗ:

- ទេ , លើសខ្ញុំខ្លាក់តែល្អដែរ, យើងមានគ្នាតិចជាងគេបើការសន្ទអន្ទ្រាក់យមិនឈ្នះ មិនបេះតែម្ដ ? មិនប្រាកដជាស្លាប់ទេបង "

លីសែជ្រួញចិញ្ចើម:

- អាទៀងរាយមិនឈ្នះ រត់ក៏ចឹងមិនរួចជាអ្នកក្លាហានទេ ។ ណ្ហើយ ! អូនប្រុសកុំទៅនាំតាប់កិត្តិយស....

- ទេ, បើបងមិនចង់កប់កេរ្ដិ៍ឈ្មោះខ្ញុំមិនរត់ទេ ។

ចាក់សាននិងលីសែសេស់ផ្លូវបន្ទើងដាន់ស៊ីផាន កញ្ចៀះសូកដាក់គ្នាត្រីក្បាលចាល់បំពោះហើយបន្តដំណើរទៅមុខទៀត ។ មិនយូរប៉ុន្មានទៅដល់ភូមិនេសាទជាទីតាំងក្រុមប្លុកដែក, តែមិនឃើញខ្លួកដំពោរពេញទៅដោយខ្មោចក្រុមត្រីហោះនៅមាត់ទន្លេទេ ។

ភូមិចាំងមូលស្ងាត់ច្រៀបឥតឃើញមនុស្សសោះ, ចាក់សាននិងលីសែសក្ដិមួយគ្រួសទៅបង្ហើរកម្រងផ្ទះស្បូវមួយ ។

ចាន់សានបើកទ្វារទ្វាក ដើរចូលទៅក្នុងបន្ទ្រានចាយ ក្រឡេកជុំវិញខ្លួនសញ្ញឹងគិតបន្តិចទើប

លើកពានទឹកមួយធំរាក់ទៅម្ខាង ។ នៅក្រោមពានទឹកគេឃើញកន្លែងមួយពិបាំ, ល្វីសើចាប់កន្លែងលើកឡើងភ្លាមៗក្រោក ! រំលេកបន្ទះដែកយ៉ាងធំលេចឡើងក្រោមដីច្បាស់ហើយ ។

ចាន់សានលោតចុះទៅក្រោមមុន ទើបល្វីសើចុះតាមក្រោយ ។ ស៊ីកោចផ្ទាក់កេតដោយឆឿនដួលទិនស្ងៀមស្ងាត់ រួចលោតចុះទៅតាមគេទៀត ។ ភ្លាមនោះឮសម្លេងមនុស្សស្រែកសួរៈ

— អ្នកណាហ្នឹង ?

ព្រមទាំងសន្លឹកខ្យល់បក់មកផង ។ គឺជាឡូកដែកក្លែងក្លូកបាក់គ្រប់គ្រងបាន ។ គាត់ត្រូវបណែទះដងច្បូកផាំង ! ផងពីរនាក់ដួលព្រងើយត្រោះពេញផែន ស្លាប់មួយរំពេចក្រោមគុជកំភ្លើងកាត់ ។

រូងនេះមានច្រកខាងក្នុងទៅទៀតផង តាមផ្លូវផ្លឹងសំពប់ក្ដីស្ងួតហើយងាក់ចេញតាមផ្លូវនីមួយៗ មានអ្នកយាមពីរនាក់កាន់ច្បូកដែក ។ ចាន់សានដើរនាមុខត្រាប់តែក្រវាត់បំពេះអ្នកយាមពីរនាក់ដួលស្លាប់មួយរំពេច ។ កាយវិការគាត់រហ័សហើយច្បាស់លាស់ណាស់មិនងាយប្រឹងលស្មៀតទីពីរទេ ។ ស៊ីផានចហាកក្អួន ទឹកថា:

—បងចាន់សានចេះមន្តអាគមសិល្បសាស្ត្រអ្វីទៀតទេ ? បើគាយខ្លួនសិល្បៈច្បាប់ហានទេ [illegible] ខ្ញុំនឹងតែជាងទីទមិនហួសបី, ទីនមកហួសប្អូនទិនលោកគ្រប់ឃ្លាយ ?

ខណៈនោះនាយភ្ញាក់ព្រើតនិងសម្លេងអ៊ូអរ ត្បិតមានមនុស្សមួយក្រុមកំពុងដើរមកពីក្នុង ។ ចាន់សានបោះជំហានមួយទៅមុខយ៉ាងលឿន, ជនមួយក្រុមដែលកំពុង [illegible] ស្ងាំនភ័យស្លុតត្រូវ ។ ចាន់សានស្រែកសួរ:

លោកនាយក្រុមនៅឯណាទេ?

ជនម្នាក់មានរាងក្រញូស [illegible] :

[illegible] សូមអភ័យទោស ។ [illegible] ក្រុមច្បូកដែក [illegible] រៀបចំពិធីរាប់របៀបអស់លោកឲ្យបានរួចរាល់ ។ ឬ... នៅមានអ្វីទៀតឬ ? សូមអញ្ជើញ !

ចាន់សាន [illegible] ។ ស៊ីផានគ្រវីយ [illegible] ព្រោះនៅតាមផ្លូវចូល [illegible] មិញ ចាន់សានសម្លាប់អ្នកយាមអស់ពីរនាក់ហើយ, [illegible] ,

ហេតុអ្វីគេនៅស្ងៀម ហើយអញ្ជើញផឹកស៊ីទៀត ?

នាយក៏យកក្ដុកក្ដាក់តែម្នាក់ឯង , ឃើញហាន់សានឌិនលីស៊ែ បោះជំហានចូលទៅរោងយក្សា ហាន នាយមិនអាចរុញរាបាន ក៏ដើរចូលក្រោយតាមគេដែរ ។

ជនមាឌធំក្រអាញដើរមុខនាំផ្លូវដោយគោរព ; ឯសេនាក្រុមច្បូកដែកក៏ឈរតំរៀបផ្លូវកាន់អាវុធ គ្រប់ៗគ្នា សងខាងផ្លូវដែរ ។

ហាន់សានឌិនលីស៊ែដើរកាត់មុខអ្នកកាន់ច្បូកដែកធ្វើព្រងើយ ។ ទៅដល់គ្រុំមួយស្រាប់តែព្រិល ភ្នែកស្រវាំងនឹងពន្លឺភ្លើងក្នុងបន្ទប់ធំនេះ ។ ព្រោះគេអុជភ្លើងច្រើនឲ្យភ្លឺដូចនៅខាងក្រៅក្រោមពន្លឺព្រះ អាទិត្យដែរ ។ បន្ទប់នេះមានអ្នកកាន់ច្បូកឈរបំរើជាប្រចាំមុខមាត់ ១ ។ ស៊ីផានក្រឡេក ខ្វាច់ប៉ះខ្សែភ្នែកគេឃើញពន្លឺសាហាវ នាយក៏យកក់ស្លុត ហើយស្លប់មុខឬកទាំងទោះណាស់ ។

ជនមាឌធំអញ្ជើញហាន់សានឌិនលីស៊ែ អង្គុយកៅអីម្នាក់ឯង ។ ហាន់សានចង្អុលកៅអីមួយក្បែរ ខ្លួនប្រាប់ស៊ីផាន :

-ប្អូនប្រុស , មកអង្គុយត្រង់នេះ ។

លុះអង្គុយស្រួលបួលហើយ , សេនាប្អូនប្រាំនាក់ស្លៀកពាក់ខៀវ លើកកែវស្រានិងម្ហូបក្លែម មកដាក់លើតុ ចំពោះមុខអ្នកទាំងបីនាក់ ។ ហាន់សានឌិនលីស៊ែ ឥតរវល់មើលម្ហូបអាហារឬស្រា ទេ , គេគ្រវាសដៃឆ្វេងបោះវត្ថុមួយរបបលើតុព្រមគ្នានឹងសូរសាំង ! ផ្លាកដែកពីរបន្ទះធ្លាក់ផាប់លើតុ ចំមុខជនមាឌធំដែលនាំផ្លូវមក ។ ផ្លាកទាំងពីរកប់ក្នុងសាច់ឈើ ដូចគេបោះដាក់តាំងពីយូរ ជាគ្រឿង លំអ

ផ្លាកស្ពាន់មួយមានឆ្លាក់រូបមនុស្សស្រស់ច្រហាញមួយទៀតឆ្លាក់មុខអាចសាហាវដូចផ្លាកស្ពាន់ពីរលើ ផ្ញាំងខ្ទុកក្រុមត្រីហោះបេះបិទ ។

ជនមាឌធំក្រអាញប្រែទឹកមុខស្លុះស្រេកក្រោក ! ច្បូកដែកប៉ះគ្នាច្រាំងកឹងកាំងទាប់ភ្លាម ។ គឺ សេនាក្រុមច្បូកដែកកាប់រយលើកអាវុធឡើងចូលទៅមុខប្តូរជំហានដូចណាត់ , ស៊ីផានខឹង :

-អញ្ចាញុះ ! ពួកគេច្រនឹងឡប់ប្រែប្រួលទាំងហើយណា ! បន្ទប់ក្រោមដីនេះចង់នាំយកគ្រោះកាចទេ ។

នាយក៏យប់ថ្នាក់ថែកមើលបរិធរមកាំពីរភ្លាម ។ ហាន់សានឌិនលីស៊ែញញឹមមុខដូចឈ្មួញតាហាក់ ឥតមានរឿងហេតុអ្វីកើតឡើងសោះ ។

ពេលនោះជនមាឌធំបង្ខឹបទៅតាន់មុខស្រងូត:

– បើដូច្នេះពួកយើងមិនបាច់តក៏អីទេ ។

តាន់សានសើចញឹមៗ:

– លោកនាយក្រុម, យើងខ្ញុំមកសុំអញ្ជើញលោកនាយទៅពិសាបបរវិទក្តិកនៅខាងណោះម្តង ។ យើងគ្មានបំណងផ្សេងទៀតទេ, សូមលោកនាយកុំសង្ស័យ ។

ជនមាឌធំក្រាញជានាយក្រុមប្លន់ដែកមែន ។ គាត់ក្រញូវកបន្តិចទើបលើកដៃទន្សាំង របើកផ្ទាកស្ពាន់តាំងពីចេញមកវិញភ្លាម ។ គាត់រើសផ្ទាកស្ពាន់តាំងពីរដាក់ហោប៉ៅ ទើបឆ្លើយ :

–ខ្ញុំបាទគ្រាក្លូវយ៉ាំសុំទទួលសេចក្តីអញ្ជើញនេះ ។ តាន់សានលើកមេដៃពោលសរសើរ:

–អរគុណលោកនាយក្រុមណាស់, គោលបំណងយើងខ្ញុំបានសម្រេចដូចក្តីប្រាថ្នាហើយ

សមាជិកជាច្រើនស្រែកឡូឡាប្រចូកប្រចល់គ្នា :

លោកនាយក្រុមយ៉ាំជាអ្នកដឹកនាំពួកយើង ហើយយើងខ្ញុំជាសមាជិកក្រុមប្លន់ដែក, យើងមិនព្រងើយកន្តើយឲ្យលោកនាយក្រុមរែកអម្រែកដ៏ធ្ងន់តែម្នាក់ឯងទេ ។

ស៊ីផានស្គាល់ជាក់ជាសម្តេច "លោកបង្វ" ដែលសម្លាប់គេពីរនាក់នៅក្នុងទូកក្រុមត្រីហារក្លាម នាយរឹតតែភ័យស្លុតព្រលឹងថែមទៀត ទឹកញើសញើតលោកបង្វដែលកាចសាហាវយង់ឃ្នងលើសមនុស្សធម្មតា ។

នាយក្រុមយ៉ាំពោលទាំងញញឹមស្ងួត:

– រឿងតាំងស្លាប់អសារបង់គ្មានប្រយោជន៍ទេ ។ ខ្ញុំគិតរួចស្រេចហើយ សូមលោកប្អូនកុំមាត់ច្រើន ។

ពោលចប់ គាត់លើកចានស្រាចាក់ឲ្យតាន់សានហុចទាំងដៃញញើញញ័រ កំពប់ស្រាពេញលើតុ ។

តាន់សានសើចចំអក :

– ខ្ញុំឮល្បីថា លោកនាយក្រុមយ៉ាំក្លាហានអង់អាចណាស់ សម្លាប់មនុស្សឥតព្រិចភ្នែកទេ, ហេតុអ្វីថ្ងៃនេះលោកភ័យញ័រសម្បើមម្ល៉េះ ?

គាត់លើកកែវស្រាប្រុងផឹកស្រាប់តែប្តូរកែវពីដៃបេចខ្ចាយ ។ គាត់ចម្រេកខ្លួនលើបង្អែកកៅអី ធ្វើឲ្យស៊ីផានភ្ញាក់ព្រើតស្លុតភ្លាម :

-លោកបង យ៉ាង ម៉េចហើយ ?

រួចនាយវ៉ៃនៅសួរលីសែទៀត :

- លោកបងទីពីរម៉េច ... ម៉េចក៏គាត់..,

ពេលដល់ត្រង់ណេះនាយឃើញលីសែទន់ខ្លួនរអិលធ្លាក់ទៅក្រោមតុ ។ មាណពគានកើតភ័យខ្លាំងឡើង, រលះរលាំមិនដឹងគិតធ្វើយ៉ាងណា ។

ឯនាយក្រុមយ៉ារ ដំបូងនឹកស្មានថាបានសាននិងលីសែធ្វើឫកបង្ខំសាកល្បងគាត់ តែបន្ទាប់មកឃើញបានសានមានទឹកមុខក្រហមឆ្អាំង, ដកដង្ហើមញាប់ស្អក ហើយលីសែបើកភ្នែកទាំងពីរសស្លែក, មុខឡើងពណ៌ស្វាយ ហាក់ត្រូវថ្នាំបំពុលអ្វីម៉្យាង ក៏ត្រេកអរក្រៃលែង ។ គាត់មិនបានបញ្ចេញប្រតិកម្មភ្លាមទេ ធ្វើជាសួរ:

- យ៉ាងម៉េច ? លោកប្រហែលជារិះគន់ថា - ស្រាខ្ញុំមិនសូវឆ្ងាញ់ហើយ! ចុះលោកខាងណោះពិសាទេ ?

ហើយប្រែទៅចាក់ស្រាឲ្យលីសែតែឃើញជននេះរួញខ្លួនក្រញង់នៅក្រោមតុកំពុងកម្រើកខ្លួនត្រនៗ ។ ស៊ីផានភ័យស្លន់ប្រញាប់ចាប់ត្រកងលីសែឲ្យក្រោកឡើង សួរថា ·

- លោកបងទីពីរ! បង .. បងមិនស្រួលឬ ?

មាណពមិនដឹងថាស្រាដែលនាយផឹកជាមួយបងធំជាស្រាថ្នាំដ៏មានជាតិពិសយ៉ាងសាហាវឡើយ។ ដ្បិតតាមកម្រិតកម្លាំងធាតុនៃជនទាំងពីរកាលណាផឹកបានបីផ្តិកត្រូវបំរើនកម្លាំងរំលាយជាតិពិសសិន ទើបអាចផឹកទៅទៀតបានតែមិនដូច្នេះអ្នកទាំងពីរ ផឹកប្រាំបីប្រាំបួនផ្តិកបន្តបន្ទាប់គ្នាហើយ នៅមិនទាន់រំលាយពិសពីក្នុងខ្លួនទៀត ។ ហេតុនេះជាតិស្រាក៏ឡើងហួសកម្រិតតែគេទំប្រឹងទប់ទល់ទាំងត្រដរហើយធ្វើឫកដូចគ្មានឈឺចាប់អ្វីបន្តិចសោះ ដើម្បីលាក់មិនឲ្យមាណពដឹងថាខ្លួនផឹកស្រាចាញ់នាយ ។ ម្យ៉ាងទៀតគេនឹកត្រេកអរដោយយល់ថាកម្លាំងធាតុខ្លួនល្អតលាស់ណាស់ ផឹកស្រាពិសច្រើនម្ល៉ឹងៗ ហើយនៅតែពុំឈឺរមួលខ្លួនទៀត ។

គេមិននឹកស្មានថា ថ្នាំបន្សាបដែលបានលេបនោះមានលក្ខភាពត្រឹមទប់ទល់ជាតិពិសមិនឲ្យធ្វើទុក្ខបណ្តោះអាសន្នប៉ុណ្ណោះសោះ ។ បន្ទាប់ពីការទំស្រួតដំណើរមួយរយៈពេលមក ជាតិពិសក៏ចាប់ធ្វើទុក្ខយ៉ាងទាន់ហន់ ។ ពេលនេះបានសាននិងលីសែឈឺពោះខ្លាំងពន់ប្រមាណ ឈឺស្អក

ពេញព្រាណ ។ អ្នកចាំងពីរដឹងខ្លួនធ្លាក់ក្នុងគ្រោះមហន្តរាយ ក៏ប្រញាប់បំរើនកម្លាំងជួយសម្រាលការឈឺចាប់ ព្រោះបើបណ្ដោយឲ្យជាតិពិសជ្រួតជ្រាបដល់បេះដូងប្រាកដជាដាច់ខ្យល់ស្លាប់ភ្លាមពុំខាន ។ តែបង្រ្គួនឧបទ្រពអ្វីថ្នាំបំពុលធ្វើឲ្យអ្នកក្នុងគ្រាដ៏អាសន្នដូច្នេះ គឺជម្រុញឲ្យជំរិតគេចាំងពីរនោះធ្លាក់ក្នុងកណ្ដាប់ដៃសត្រូវយ៉ាងងាយ ទោះជាបន្ទ្រាំទ្រទឹងជាតិពិសបានក៏ដោយមិនរួចពីក្ដីស្លាប់ដោយសារពួកច្បូកដែកដែរ !

នាយក្រុមច្បូកដែក, «បង់វួ» ព្រមទាំងសមាជិកទាំងអស់ឃើញចាងសាននិងលីសែផ្លូលប្រកាច់ប្រកិនបែកញើសជោកខ្លួន បញ្ចេញការករៈឈឺចាប់ឥតឧបមាដូច្នេះ ក៏កើតក្ដីឆ្ងៀងឆ្ងល់ជាខ្លាំង ។ ដោយធ្លាប់គោរពស្ញើបក្ដីនាមល្បីឈ្មោះនៃពួកចាំងពីរ ចាំងពីរដើមក ទោះឃើញទុក្ខសណ្ឋានេះ ក៏នៅមិនហានផ្ដេសផ្ដាសដែរ ។

ស៊ីផាន់ស្រែកទាំងអន្ទះអន្ទែង :

— លោកបងចាំងពីរស្រវឹងស្រា ឬ មានជម្ងឺអីមកបៀតបៀន ?

ចាងសាននិងលីសែបិទមាត់ជិតចំរើនកម្លាំងតទប់ទល់ជាតិពិសរៀងខ្លួន ។ មិនយូរប៉ុន្មាន គេឃើញផ្សែងសហុយលើក្បាលគាត់ដូច ១ គ្នា ។ លោកនាយក្រុមច្បូកដែកយល់ការច្រើនជាងគេក៏ពោលតប ៗ :

លោកប្អូនវួ, អ្នកចាំងពីរហាក់យុទ្ធសិល្បៈខុសទំនង ហើយមានប្អូសធំណាស់ បានជាចំរើនកម្លាំងទប់ទល់បៀមហ្នឹង ។ ពួកយើងចាំអីទៀត ? ចូលទៅ !

«ល្បងវួង» ទ្រូងអរណាស់តែមិនហ៊ានចូលមុនទេ ។ គាត់លើកច្បូកដែកបំរើនកម្លាំងកាយពោលរើសំដៅចាងសាន, ចាងសានគ្មានកម្លាំងនឹងកាត់កំឡៀងខ្លួនគេចទៅរួចទេ ។ ឮស្នូរភ្លូស ! ច្បូកដែកវត់ចុកស្មា គាត់បាញ់ឈាមក្រហមប្រាល ។ ស៊ីផាន់បុកពោះភ័យ ។ ស្រែកតំហក:

— ឯង... ឯងធ្វើអី ? ហ៊ានធ្វើបាបបងយើងអញ្ចឹង ?

ក្រុមច្បូកដែកឃើញនាយនៅក្នុងភ័យស្ញប់ស្ញែងដូច្នេះ គ្មាននរណាយកចិត្តទុកដាក់នឹងនាយទេ ; ស្មានថានាយមិនចេះគុនវិជ្ជា ។ ឥឡូវឃើញ «បង់វួ» ពោលច្បូកត្រូវស្មាចាងសានដោយងាយបែបនេះ គេមានកម្លាំងក្រេវក្រាសគ្រប់គ្នា ។

ឮស្នូរឈឹប ១ ! ច្បូកដែកបីស្រែកអាកាសចូលប្រជ្រង់ស៊ីផាន់ណាលគ្នា ។ មាណព

លើកដៃឆ្វេងកាត់ធ្លាក់ព្រួញពីរ , ដៃម្ខាងនាយល្អក់ចាប់ព្រួញទីបីជាប់ ហើយស្ទុះវិលទៅឈរតាំងមុខ ចាំងសាទនិងលីសៃ

ពេលនោះ មានព្រួញប្រាំព្រួញសំដៅមកទៀត, នាយលើកព្រួញក្នុងដៃឆ្វេងកាត់វាយទម្លាក់ព្រួញទាំងប្រាំខ្ទាតទៅក្រោយអស់រលីង ។ ក្នុងចំណោមនោះមានព្រួញពីរប៉ុនទៅប៉ះក្បាលសមាជិកក្រុមព្រួញដែកម្នាក់ធ្លាយខួរស្លាប់ភ្លាម , ម្នាក់ទៀតធ្លាយទ្រូងប្រកាច់ត្រឡប់ ! នាយក្រុមយ៉ាវឃើញបន្ទប់តូចបង្អៀតមិនស្រួលរាយក្បួនព្រួញដែកប្រយុទ្ធ ហើយឃើញសហការីស្លាប់ចាន់ចាន់ដូច្នេះ ក៏ស្រែកឃាត់:

— បងប្អូនកល់គ្នាឈប់សិន, ទុកខ្ញុំកំចាត់ការក្មេងឥតពូជនេះពេលមុន សឹមគិតគ្នាតទៅទៀត !

ពេលឈប់គាត់បន្ទន់ចង្កេះល្អុកដៃសងខាងស្ទាបដើងខោបន្តិចរួចដើបឈរត្រង់ខ្លួនវិញ បាន កាចិតស្នៀតពីរកាន់នៅដៃភ្លាម ។

សមាជិកក្រុមព្រួញដែកទាំងអស់នាំគ្នាដកថយទៅឈរផ្ទឹកជញ្ជាំងព្រមទាំងស្រែក:

—គនយើង, ចាំមើលលោកនាយក្រុមសម្លេះកាក្មេងឥតពូជនេះហ៊ឺយ !

សម្រែកនេះលាន់ឮពេញក្រោមដី ។ នាយក្រុមយ៉ាវបន្ទន់ខ្លួនស្ទុះភ្លែតទៅជិតស៊ីផងនរហ័សដូចផ្លេកបន្ទោរញែកកាំបិតស្នៀតមួយលើមួយក្រោមតម្រង់មុខនិងចង្កេះអ្នកកម្លោះ ។ ស៊ីផងនឥតស្មានទុកជាមុនថានឹងល្ហុតកគ្នាតមាត់ស្រែកអូយ ! ហើយស្ទុះទៅមុខមួយជំហានបែកព្រួញដែកពីដៃត្រឡប់កាំបិតស្នៀតពីរកន្ទួនត្រង់ដៃនិងចង្កេះព្រមគ្នា ។

នាយក្រុមយ៉ាវភ្ញាក់ផ្អើល ដោយឃើញច្បាស់ថាមាណពគ្មានបេះយុទ្ធសិល្បះសោះទេ ។ គាត់ស្រែកកំហួចិត្តហើយបង្វិលខ្លួនវិលខ្ទាល់ចូលទៅម្តងទៀតដូចឆ្មាប្រុងស្ទុះចាប់កណ្តុរ ។ ស៊ីផងនក្តាក់ស្មារតីលើកដៃត្រវាសតាមស្នៀតគុនដែលនាយហាក់រៀនហឿនម្នាក់ឯងលើកោះវៀងជ្រៃ ។ ព្ញសួរ ! បាតដៃនាយបញ្ចេញកម្លាំងមហិមាញ្ញេច្រានាយក្រុមយ៉ាវឲ្យថយក្រោកៗ ដោយហេតុគាត់ជប់ជង្ហើម ។ សំណាងល្អស៊ីផងនមិនទាន់ចេះប្រើស្នៀតគុនស្នាក់ជ័ទាញទើបមិនវាយលុកវែម កុំអីលោកនាយក្រុមវិនាសហើយ !

គាត់ពិចារណា :

—អាក្មេងនេះចេះយុទ្ធសិល្បះដែរតើ ! ទុកធ្វើអីទៀតនាំទើសដៃ ? សម្លេះវាចោលភ្លាមទៅ !

Khmer Story Lovers



គាត់យារកាំបិតស្នៀតរុញពីក្រោមពីលើពីចំហៀងរហ័សរៀតៗសំដៅមាណពទៀត ។

ស៊ីផាន់មានរបួសស្រាលនៅដៃស្តាំ, តែគ្រាន់បន្តិចឈឺធៀបៗ ។ អម្បាញ់មិញ នាយជាល់មួយដៃ ធ្វើឲ្យនាយក្រុមយ៉ាវគេចថយក្រោយដែរ ក៏យល់ថា :

-ស្នៀតផ្តេសផ្តាសដែលយើងនឹកឃើញលើកោះផ្សេងៗអាចប្រើការបានដែរហ្ន៎ !

ពេលនេះឃើញនាយក្រុមយ៉ាវលោតសន្ទុះមកទៀតយ៉ាងសាហាវ នាយគេចរំកិលយារដៃជាល់ខ្នងគាត់វិញភ្លាម ។ នាយក្រុមចៀកដែកដឹកនាំក្រុមបក្សយួរហើយតែចេះយុទ្ធសិល្បៈគ្រាន់បើដែរ, ពេលនេះគាត់ភ្ញាក់ព្រើតលែងហ៊ានប្រមាថក្មេងព្រោះឮសូរខ្ទឹកខ្យល់មកពីក្រោយខ្នងពេក ។ ភ្លាមនោះគាត់បញ្ចេញស្នៀតគុនប្រយុទ្ធកាយលើកកាំបិតកាប់គម្រង់កន្លែងសំខាន់លើខ្លួនមាណពគ្រប់ផ្នែក

ឆាកប្រយុទ្ធកាន់តែសាហាវឡើង, ស្វាហាប់ឡើង. សមាជិកក្រុមចៀកដែកឈប់ស្រែកលើកទឹកចិត្តនាយក្រុម ទៅជារំភើបញាប់ញ័រទំពាមដានការហ៊ាយលុកនៃអ្នកទាំងពីរ លែងហ៊ានស្រែកហ៊ោ ព្រោះគេមិនដែលជួបប្រទះការប្រយុទ្ធបែបនេះឡើយ ។

ហានីសាននិនលីសែទំចំរើនកម្លាំងឆាតុទប់ទល់ជាតិពិសបណ្តើរ តាមដានការប្រយុទ្ធរវាងនាយក្រុមយ៉ាវ និងស៊ីផាន់ឥតហ៊ានព្រិចភ្នែកបណ្តើរ ។ គាត់ដឹងច្បាស់ថា ខ្លួនស្ថិតក្នុងកណ្តាប់ដៃក្រុមចៀកដែកហើយ ហើយឃើញមាណពបណ្តោយឲ្យនាសល្អកន្លងទៅច្រើនដង គាត់សោកស្តាយទិនអន្ទះអន្ទែងក្រៃលែង ។

អ្នកទាំងពីរប្រយុទ្ធគ្នាមួយសន្ទុះទៀត ទើបស៊ីផាន់យារដៃស្តាំទះផាំង ! នាយក្រុមយ៉ាវធុំក្លិនក្រអូបឈ្ងុលច្រមុះតាមកម្លាំងដៃមាណព, គាត់វិលមុខទន់ជើងទន់ដៃដួលប្រូស , ទឹកមុខប្រែសម្បុរក្លាមមួយរំពេច ។

ស៊ីផាន់ស្រឡាំងកាំង លោតថយក្រោយភ្លាម ហើយសួរ :

- យ៉ាងម៉េចបានជាលោកដួល ?

« បងវ៉ូ » ស្ទុះរត់ទៅមើលលោកនាយក្រុមយ៉ាវ ឃើញមុខគាត់ឡើងខ្មៅអ៊ី ... ជាសញ្ញាជាតិពុលពិសសាហាវ ។ លុះដាក់ដៃលើច្រមុះគាត់ស្ទាបដង្ហើម ទើបដឹងថាគាត់ដាច់ខ្យល់ទៅហើយ « បងវ៉ូ » ទឹងក្រេវក្រោធស្រែកខ្លាំង ១ ប្រាប់គ្នីគ្នា :

-អា...ក្មេងចង្រៃនេះបេះប្រើថ្នាំពិសផងម្ល៉ឹង ? ពួកយើងចូលទៅ ! លោក...នាយក្រុមយើងត្រូវ

កាល្អិតនេះសម្លាប់ហើយ ។

សមាជិកទាំងអស់ស្រែកស្ងប់គោរទ្បើង ហើយលើកច្បូកចាក់កាប់កម្រើនសុីផានគ្រប់ទិស ។ មាណពនៅឈរទាំងមុខចាំងសានមិនបើសើផផែល ខ្លាចច្បូកដែកថ្ពាក់មកត្រូវបង់ធម៌ ។ ក្នុងគ្រាអាសន្ននេះនាយផ្តើមច្បូកដែកមួយទៀត បញ្ចេញស្បៀតតុនកាំបិតរបស់ក្រុមព្រះអាទិត្យវាយលុកសងវិញយ៉ាងសកម្ម ។ នាយបញ្ជូលកម្លាំងទៅច្បូកដែកវាយវាត់មួងៗចេញខ្យល់វីៗដូចព្យុះសង្ឃរា ។

មួយសន្ទុះសោះនាយត្រាសច្បូកដែកខ្ចាតខ្ចាយយ៉ាងច្រើន ។ ជនម្នាក់ជាសេនាឈរកើតជាងគេគ្រាន់តែបូតអាវុធពីដៃភ្លាម គេណោតក្រូងក្រមាសង្រ្គុបលើមាណព ហើយលូកដៃចាប់ខ្វាប់ខ្លួននាយឥតប្រណី ។ សុីផានឃើញគេប្រើកាយវិការសាហាវបែបនេះ ក៏ស្រាវសដៃត្រូវម៉ាំង ! តាសម្រាមចាំងជាប់នោះព្យួក្រាក ! ក្រាក ! តឺជននោះបាក់ដៃខ្ទេចដួលប្រុសលៃទំក់រើកស្រេច ។

ក្នុងសកាលបណាបលើកវើយស្ការនេះគ្មានសមាជិកណាគិតគូរពីរៀងស្លាប់រស់ទេ, គេសុះចូលវាយលុកតម្រង់មាណពទាំងដៃទទេក៏មានដែរ ។

មាណពឥតហ៊ានទៅណាឆ្ងាយពីបង្កមទាំងពីរទេ, រង់ចាំតែអ្នកណាចូលមកទើបលើកដៃទះផាំង ! ត្រូវចំឡែកណាសឲ្យតែសត្រូវណាហ៊ានមកជិតច្បាស់ជានាបទះដួលក្បាលៗគ្មានសល់ ។ លុះឃើញសុីផានទះគ្នីគ្នាដួលអស់៦នាក់ សមាជិកក្រុមច្បូកដែកស្រែកនោទ្បេ :

– អាល្អិតនេះបេះវិជ្ជាដៃពិសការចសាហាវណាស់ គតយើងប្រយ័ត្នឲ្យមែនទែន !

– លោកបងវូនិងលោកថងសុីនត្រូវអាតូចល្អិតនេះសម្លាប់បាត់ហើយ . . . ពួកយើង . . . ប្រយ័ត្ន . .

ស្រែកបានត្រឹមណោះជនម្នាក់ដួលប្រុសធ្លាក់ច្បូកពីដៃត្រូវមុខខ្លួនឯងបែកឈាមរហាម ។ ត្បិតជននេះត្រូវពិសស្លាប់យ៉ាងការណាចាកចំណាស់ដោយមុខបាចសុីផានវាយទាន់ទេ ។ ក្នុងបន្ទប់ក្រោមដីទាំងមូលសមាជិកក្រុមច្បូកដែកក៏កក់យកក់ស្លុតគ្រប់គ្នា ម្នាក់ៗថយក្រោយមួយជំហាន . .

បន្ទាប់មកព្យួស្ងប់ប្រុសៗ . . តឺគេដួលស្លាប់ម្តងម្នាក់ៗ រកដឹកខ្លួនគេមិនទាន់ផង ។ មួយស្របក់នោះសមាជិកច្បូកដែកប៉ប់រយះជេកដួលគរលើគ្នាលែងកកដង្ហើម, នៅសល់អ្នកខ្លាំងពូកែគ្រាន់តែបី បួនប្រាំនាក់ប៉ុណ្ណោះដែលទាន់បើកដៃខ្ទប់មាត់បិទច្រមុះរកច្រកចេញ ។ ប៉ុន្តែមកដល់មាត់ទ្វារបន្ទប់ គេទប់ទល់លែងបានដួលប្រុលៗប្រកាច់ត្រឹលជាច់ខ្យល់ស្លាប់ទៀត ។

សុីផានឃើញមនុស្សស្លាប់ដូចស្រមោចយ៉ាងនេះនាយទៅជាភ័យស្លាយមុខចិត្តភ្ញាក់ផ្អើល លើស

កាលនោះកូនទូកក្រុមត្រីហោះទៅទៀត ។ ដ្បិតកាលណានាយឃើញខ្មោចស្លាប់ស្រាប់មិន ប្រៀកប៉ុន្មានទេ តែពេលនេះសហជីពក្រុមចោរដែកដួលប្រុស ។ ដូចត្រូវមន្តអាគមគាថាឬខ្មោច ព្រាយបោហោពហូតព្រលឹងជាក់ស្តែងនឹងភ្នែកពេក នាយភ័យណាស់ ។

ស៊ីផានទឹកឃើញសំរដ៏ក្រុមចោរដែកដែលថានាយចេះប្រើពិសពុល ក៏លើកបាតដៃមើលម្តងទៀត ឃើញស្នាមមូលបកណ្តាលពណ៌ក្រហមឆ្អៅនឹងចំណុចទៀវតូចៗជាច្រើននៅជុំវិញ ។ មើលយូរ ទៅនាយស្រៀវស្អីតខ្នងឯងចង់ក្អួតចង្អោរ ព្រោះបាតដៃចាំងពីមានពណ៌សម្បុរដូចស្បែកពស់បូកគ្រប ហើយច្រមុះនាយក៏ក្លិនចង់ស្ញែក ហាក់ដូចគេស្អុយបន្តិចស្អុយបន្តិចគួរខ្ពើមរអើមមែន ។

មាណពពីរនាក់ចង់មើលបាតដៃទៀតក៏នូវម៉ែលចាន់សានមិនលើសៃម្អ៊ី ។ អ្នកទាំងពីរមាន ទឹកមុខស្រស់បស់បន្តិចវិញហើយ, តែដ្រស់នៅលើក្បាលគាន់តែក្រាស់ឡើង, ចោរដែកមួយនៅ ជាប់សាច់ស្មាចាន់សានដដែល ។ ស៊ីផានទឹកថាត្រូវហូតចោរនេះពីមុខរបួសបង់ធមិសិន ទើប បោះជំហានទៅជិតចាន់សានដកចោរយ៉ាងថ្នម, ឈាមបាញ់កលតាមមុខរបួស ។ នាយហែក ជាយអាវខ្ញុំឲ្យបង់ធមិភ្លាម ។ ចាន់សានដកដង្ហើមវែងពោលតិចៗ :

— ប្អូន . . . ត្រូវ . . . ធ្វើតាម . . . សំដីបង . . .

សម្លេងតិចៗ ហើយដាច់ៗពីគ្នាទៀត ប៉ុន្តែគាត់និយាយបានមុនលើសៃ ព្រោះជាតិពិស ចេញតាមមុខរបួសខ្លះ ។ ចាន់សានយល់ឱកាសល្អមកដល់ទើបប្រមូលកម្លាំងផ្តាំផ្ញើស៊ីផានទៀត :

— ដៃឆ្វេង... របស់ឯងសង្កត់លើ... ទីពចរលើខ្នងរបស់...យើង ។

នេះជារបៀបបញ្ចូលកម្លាំងគាត់ព្យាបាលរបួសប្តូរពុលជាតិពិសឲ្យអស់ពីក្នុងខ្លួន ។ មាណពទាំង ស្តាប់ហើយងក់ក្បាលទទួល :

— បាទ, ខ្ញុំនឹងធ្វើតាមលោកបងទាំងអស់ ។

ចាន់សានពោលបានតែប៉ុណ្ណោះ ក៏បែកញើសជោកក្បាល ឡើងទឹកមុខក្រហមស្លេកស្រកយោម ។ ស៊ីផានមិនហ៊ានបង្អង់យូរ អនុវត្តតាមពាក្យបណ្តាំបងធមិភ្លាម ។ ដំបូងនាយដោះអាវគាត់ចេញទើប ដាក់ដៃឆ្វេងសង្កត់ដើមទ្រូងលើខ្នងគាត់, រីស្តាំសង្កត់ស្មា , បញ្ចូលកម្លាំងតាមដៃឆ្វេង ហើយបឺតជាតិពិស តាមដៃស្តាំវិញ ។ មិនយូរប៉ុន្មានដៃស្តាំនាយឡើងក្តៅគាយៗ នាយយល់ថា ជួយស្រេចស្រង់ជីវិតបងធម៌ បានដូចប្រាថ្នាហើយក៏ចេះតែខំស្រូបពិសពុលយ៉ាងយកចិត្តទុកដាក់ ។ នាយផុតជីងខ្លួនពាល់តែសោះ

ថាពេលនេះជាតិពិសចូលរាតត្បាតពេញប្រាណខាយហើយ ។

ខណៈនោះស្រាប់តែឮសូរជើងប្រឹបៗ មនុស្សជាងដប់នាក់កាន់ឈ្លូកដែកគ្រប់ដៃរត់តម្រង់មកបន្ទប់សម្ងាត់ក្រោមដី ។ គ្រាន់តែមកដល់មាត់ទ្វារគេឃើញសាកសពសមាជិកនិន់ខាយក្រុម ឈ្លូកដែកពាសពេញគេភ្ញាក់ផ្អើលហួសវិស័យឥតស្មានថាបងប្អូនរួមក្រុម ស្លាប់ហោងអាណោចអាធ័មបែបនេះសោះ ក្បត់ពួកអស់នេះមានការៈយាមល្បាតខាងក្រៅ លុះមិនឮសូរស័ព្ទឬសញ្ញាអ្វីសោះក៏នាំគ្នាចូលទៅមើល ។

ភ្លាមគេឃើញស៊ីផាន , ចាង់សាន និង លីសែអង្គុយបម្រើនកម្លាំង យល់ច្បាស់ថាអ្នកទាំងបីរបួសធ្ងន់ណាស់ក៏ស្រែកថា ! កាន់ឈ្លូកស្ទុះចូលត្រូវ, ស៊ីផានស្ទុះក្រោកប្រុងតទល់ស្រាប់តែឃើញជនទាំងនោះញ័រញាក់ប្រេតក្រោតដូចមនុស្សស្រវឹងស្រារួចទន់ជើងដួលប្រុស មួយប្រហែលមួយម៉ែត្រពីអ្នកទាំងបី ។ មិនទាន់បានប៉ុន្មានម៉ាត់ផង គេដាច់ខ្យល់ស្លាប់បាត់បង់ជីវិតជាបន្តបន្ទាប់គ្នា ។ ស៊ីផានភ័យញាប់ញ័រ បន្លឺវាចាអាក់គគុប :

- បង ... ក្នុងទីនេះមានខ្មោចឬ ? យើងត្រូវ ... រត់ចាប់ឡើង ។

ចាង់សានគ្រវីក្បាល ។ ជាតិពិសបានរលាយអស់ខ្ទះពីក្នុងកាយគាត់ មិនសូវឈឺចាប់ដូចមុនឡើយ គាត់ប្រាប់មាណព :

-ឯងជួយ ... បងទីពីរតាម ... របៀបនេះផង ។

មាណពងក់ក្បាលឆ្លើយបាទៗហើយទៅជួយជំរុញពិសពីខ្លួនលីសែប្អូន ។ លើកនេះមិនមែនជាតុក្តៅទេដែលរត់ចូលបាតដៃខាយ . គឺជាធាតុផ្ទុយត្រជាក់ស្រេបទៅវិញ ។ មួយសន្ទុះលីសែដូរស្រាលបន្តិច គេជេញមាណពឲ្យទៅជួយព្យាបាលចាង់សានម្តងទៀត ។

មាណពជួយព្យាបាលម្នាក់ម្តង ១ ម៉ោងគ្នាបីសា, ទើបចាង់សាននិងលីសែអាចក្រោកឈរដើរចុះឡើងដូចធម្មតាបាន ។ នេះមិនមែនបានសេចក្តីថា ជាតិពិសវិនាសសាបសូន្យពីក្នុងប្រាណគាត់ទេ , តែជនទាំងពីរធ្លាប់ប្រើថ្នាំពិសស្រាប់ អាចទប់ទល់បានមួយរយៈខ្លួនឯងជាយស្រាយក្នុងករណីដែលមានពិសពុលក្នុងខ្លួនបន្តិចបន្តួច ។

ចាង់សាននិងលីសែឈរមើលវិការដ្ឋានខ្មោចស្រាក្នុងបន្ទប់សម្ងាត់ក្រោមដី ឃើញខ្មោចពាសពេញ ក៏ព្រឺឆ្អឹងខ្នងខ្លាចរាងដែរ ។ លុះមើលមុខស៊ីផានគេងឿងឆ្ងល់ជាខ្លាំងព្រោះក្រៅពីភ័យស្លុតនិងសាកសពចំពោះមុខ, អ្នកកម្លោះនេះឥតមានសញ្ញាអ្វីបញ្ជាក់ថាត្រូវជាតិពិសកំណាចញាំញីឡើយ ។

ស្ដេចឃ្លាំងសួរខ្លួនឯង : តាល្អិតនេះបានលេបថ្នាំឬស្អីស្មោះចិត្តអ៊ីយ៉ាងនេះ?

ត្បិតអីស្រាក្នុងឃ្លាំងទៀត ឃ្លាំងក្រហម ត្រូវមានភាពពិតអស់ជាងពាក់កណ្ដាល ។ បាន សកានធំដល់សើងកត់ប ហើយមានថ្នាំបន្សាបផង គង់ប្រួសធ្ងន់រំលាត់បង់ជីវិត ។ ឥឡូវនាយ បីតជាតិពិសបញ្ចូលក្នុងខ្លួនថែមទៀតឃើញថា ពិសមានឥទ្ធិពលសម្បើមណាស់ ហើយសមាជិកប្លុក ដែកថ្លុបេប្រួសៗស្លាប់ ដំណោយសារកម្លាំងខ្យល់ដៃតាយ៉ានោះឯង ។ ពេលនេះបរិយាកាសក្នុង បន្ទប់ទាំងមូលពោរពេញទៅដោយពិសពុល គ្រាន់តែជកដង្ហើម ក៏ទន់ដៃជើងដួលស្លាប់ដែរ ។ តាំងសានយល់ហេតុ ទើបបន្លឺថា :

-មក ប្អូនទាំងអស់គ្នា, យើងនាំគ្នាចេញពីនេះឲ្យឆាប់ ។

លីសៃទិនស៊ុនបានដើរតាមតាំងសានចេញទៅក្រៅវិញ ។ លុះចេញផុតផ្លូវបត់គេឃើញសមាជិក ប្លុកដែកកាន់អាវុធឈរច្រើនព្រាំង អើតក្បាលមើលមាត់រូងស៊ើបដំណឹង ។ គ្រាន់តែឃើញអ្នកទាំង បីចេញមកគេស្រែកហៅ! លុះចូលមកឡោមព័ទ្ធជុំជិតភ្លាម ។ អ្នកខ្លះគំហក ÷

-លោកនាយក្រុមទៅណា ? ម្ដេចលោកមិនចេញមក ?

តាំងសានក្លែងទឹកមុខញញឹមញញ្ញាយឆ្លើយតប:

-លោកនាយក្រុមនៅក្នុងបន្ទប់ខាងក្រោម. ឯងចូលទៅ !

ជនម្នាក់សួរ :

- ហេតុអីពួកឯងចេញមកមុន ?

- អើ, រឿងអីយើងមិនដឹងដែរ, ពួកឯងចូលទៅមើលផ្ទាល់ចុះ ។

ពេលបប់គាត់លូកដៃប្លាមអាវសមាជិកក្រុមប្លុកដែកម្នាក់មួយ ហោះចូលក្នុងផ្លូវក្រោមដី ។ ជនទាំងពីរហោះជុំពាំតួរម៉ានកម្លាំងកាយធ្ងន់ធ្ងរ មិនដឹងហេតុអ្វីគ្រាន់តែបានសានប្លាមជាប់ក៏កម្រើក ខ្លួនលែងរួចតែម្ដង, ម្ល៉ោះហើយតាំងសានគ្រវាត់រុញបក់ណ្ដាប់ចំបើងចូលក្នុងរូងដីផុត ។

អ្នកឯទៀតក៏ភ័យស្ទុះស្រែកហេ ! លើកប្លុកដែកសំដៅតាំងសានឥតខ្លាចស្លាប់ ។ តាំងសាន ឥតគេចទេ, គាត់លូកដៃទទួលពីរនាក់ទៀតឲ្យមកអាវចាប់ក្រវាត់ទៅក្រោយប្រួស ! កាយវិការ នេះរហ័សប្លែក ធ្វើឲ្យពួកប្លុកដែកបាក់ខ្ទុយទាំងអស់, ប្រញាប់ដកដៃថយក្រោយវិញខ្លាចត្រូវគ្នាឯង ។ ស៊ីផុនឈរនៅម្ខាងមើលតាំងសានលូកដៃចាប់មនុស្សដូចខ្លែងចាប់កូនមាន់ឥតខុសមួយផ្ទះ នាយក្បាក់

-ឆ្លើយជាខ្លាំងនឹកថា :

- ក្នុងលោកយើងនេះមានយុទ្ធសិល្បៈពូកែដល់ថ្នាក់ហ្នឹងផងឬ ? បើធៀបប្រៀបនឹងធម៌រូបនេះទៅនឹងលោកគ្រូប៉ាយ, ម្ចាស់គុម្ពស្ពានសាំនស៊ុ, បងប្អូនគ្រូកូលទីង និងយាយសាវណ្ណយប្រហែលគ្មាននរណាស្មើគាត់ទេដឹង ?

ក្រឡេកមើលលីសៃខាយឃើញគេឈរក្រពាត់ដៃធ្វើព្រងើយ ។ ចាន់សានចាប់ទ្វារសមាជិកប្រុកដែកប្អូនជប់ទាក់ទៅក្រោមទៀត ទើបបង្វិលខ្លួនទៅក្រោយជនទាំងនោះទាប់ឡាម អ្នកណានៅឆ្ងាយពីមាត់រូងឲ្យចូលទៅផ្ទុំគ្នាក្នុងខ្ទមស្បូវហើយបង្ខំឲ្យគេចុះទៅកាន់បន្ទប់សម្ងាត់ក្រោមដី ។ ជនទាំងអស់ឃើញស្នាដៃចាន់សានពូកែចំឡែកក៏ស្រែកបបួលគ្នា :

— ចាប់រំកនយើង ! ទៅ !

គេនាំគ្នាសំដៅមាត់រូងចុះតាមផ្លូវក្រោមដីអស់គ្មានមួយរំពេច ។

ស៊ីផានឃើញផ្លូវចុះយល់គ្រោះថ្នាក់ ក៏ទំស្រែក :

-នៅក្នុងនោះមានគ្រោះថ្នាក់ធំណាស់, កុំចូលទៅអី !

គ្មាននរណាស្ដាប់ពាក្យខាយទេ ព្រោះគេត្រូវការទៅរកលោកឆាយក្រុមក្នុងបន្ទប់សម្ងាត់គេយ៉ាងម៉េចហើយបានជាស្ងាត់ឈឹង ? ត្រូវចាន់សានចាប់បង្ខំទៀតគេនាំគ្នាមុះស្រទៅយ៉ាងផងដឹងថាក្នុងបន្ទប់នោះសុទ្ធតែជាគំពិសពាចសាហាវអស្ចារ្យទេ ឡើងហើយគេដើរគ្រោះដួលស្លាប់បន្តបន្ទាប់គ្នាដូចសមាជិកប្រុកដែកឯទៀតដែរ ។

ស៊ីផានងឿងឆ្ងល់ច្រើនក្លែងណាស់ថាហេតុអ្វីពួកនេះដួលស្លាប់ទទេៗ ? រហូតអ័បទ័ពមិនទាំងពីរណោះ ? ឬបំផុតតើហេតុអ្វីចាន់សានបង្ខំគេឲ្យចុះទៅស្លាប់ក្នុងបន្ទប់ក្រោមដី ?

ខាយឆ្ងល់គ្រប់មិនដឹងសួរបញ្ជាក់ហេតុមួយណាមុនក៏ស្រែកហៅទទេ:

— លោកបងចាំងពីរអើយ !

ចាន់សានស្រែកដូចភ្ញាក់កន្ត្រាក់ថា:

— យី ! មាននរណាមកពីនោះទៀតហើយ !

ស៊ីផានងាកចាំងមើលឥតឃើញស្រមោលមួយសោះ , ខាយសួរវិញ:

— មនុស្សឯណា ?

ផុតកន្ទាត់និងសំគមឥតឆ្លើយ, មាណពនាគក្រោយស្រាប់តែបាត់បង់ធម្មតាំងពីក្បាលដូច អោយ៖ បំបាំងកាយ ។ នាយចំងល់ស្រែកហៅ៖

- លោកបងអើយ! ទៅណាអស់ហើយ ?

មាណពស្រែកហៅស្អកតតពុំឆ្លើយសោះ កំដើរចូលគ្រប់ផ្ទះស្បូវក្នុងភូមិនេះសាទរកមើលឥត ឃើញមនុស្សម្នាក់សោះ ។

ពេលនេះព្រះអាទិត្យរះខ្ពស់ចោលរស្មីក្រហមឆ្អៅលើទឹកទន្លេ ព្រមពាំងភូមិនេះសាងងឹតស្ងាត់ជ្រងំ ។ នៅសល់តែស៊ីផានម្នាក់គត់, នាយនឹកស្រាយទៅដល់សាកសពសមាជិកក្រុមឃ្លុកដែលស្លាប់យ៉ាងទាន់ហាន់ ខ្លាំងលើសជប្លីអាសន្នរោគទៅទៀត ។ នាយភ័យតក់ស្លុតរកើលពាក់ ក៏ស្រែកវ៉ាសរត់ ត្របាញ់ជើង ...

មាណពរត់ឥតឈប់ក្រោយដូចមានព្រាយបិសាចដេញតាម, បានប្រហែលដប់យោជន៍ទើបហ៊ាន បន្ថយជើង លើកបាតដៃមើលម្តង ។ នាយធូរស្រាលក្នុងចិត្តមួយរំពេច ដោយឃើញចំណុច ក្រហមនិងខៀវស្រពោនបន្តិច មិនជាអាក្រក់មើលដូចមុន

ហេតុការណ៍នេះបណ្តាលមកពីនាយមិនចេះប្រើប្រាស់កម្លាំងធាតុតាមក្បួនខ្នាត ម្ល៉ោះហើយជាតិពិស រតែមកផ្តុំនៅបាតដៃ មិនរួចពីរត់ចូលតាមសរសៃសសូងវិញបន្តិចម្តង ។ ប៉ុន្តែដោយនាយមានកម្លាំង ធាតុស្អកស្គម្ភស្រាប់ទើបមិនមានគ្រោះថ្នាក់ដូចគេ បែរជាកើនកម្លាំងខ្លាំងពូកែទៅថ្ងៃក្រោយជាលំដាប់ វិញ ព្រោះកាលណានាយចម្រើនកម្លាំងប្រើការ ជាតិពិសត្រូវលាយបន្តិចម្តងៗដល់គម្រប់សែសិប ប្រាំបួនថ្ងៃទើបអស់ពីក្នុងខ្លួន ។

ស៊ីផានធ្វើដំណើរទៅមុខឥតគិតទិសដៅអ្វីទេ ។ ដើរទៅៗដល់ទន្លេឈានកាន់ដៃវែង, នាយដើរតាមមាត់ទឹករហូតដល់ថ្ងៃត្រង់ទើបដល់ទីប្រជុំជនមួយ ។ មាណពស្រស់ស្រូបបាយពី អាហាររួចទើបបន្តដំណើរទៅទិសខាងកើត, ចេះតែដើរដូចខេសបចរកំសាន្តកាយតែព្រោះនាយគ្មាន គោលដៅហើយគ្មានកិច្ចការអ្វីត្រូវបំពេញផង ។ ពេលព្រលប់នាយមកដល់កន្លែងមួយមានព្រៃ ក្រាស់ឃើញអាស្រមមួយធំសង់នៅកណ្តាលព្រៃ មានចាំងផ្លូវក្រាលថ្មយ៉ាងស្អាតសំរាប់ដើរចូលទៅ ផង ។ ពេលនោះឥស្សីពីររូបស្ពាយដាវដើរចេញមក ។ (នៅមានត)

ដំកល់ទុកតាមលេខ ៣៨០ ចុះថ្ងៃទី ៣ ៦ - ៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់

Khmer Story Lovers